# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និងដោះស្រាយការងារពាក់ព័ន្ធនឹងការអនុវត្តលើគំរោងសាងសង់ផ្លូវជាតិលេខ ៦៧ (ប្រកសាង៉ុំ អន្លង់វែង សៀមរាប )

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-តាមស្មារតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីចំរុះ កម្ពុជា-ថៃ នៅខេត្តសៀមរាប និង ខេត្តឧប៊ុនរាជធានី កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣

-យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និងដោះស្រាយការងារពាក់ព័ន្ធនឹងការអនុវត្តលើគំរោងសាងសង់ផ្លូវជាតិលេខ ៦៧ (ប្រកសាង៉ុំ អន្លង់វែង សៀមរាប) ដែលមានសមាសភាព ដូចខាងក្រោម :-

| | | |
|---|---|---|
| ១-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-ឯកឧត្តម **វ៉ា គឹមហុង** | ប្រធានគណៈកម្មាធិការចំរុះ កិច្ចការព្រំដែន | សមាជិក |

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | **ញាណនា ឡេង** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម | **រស់ បូរ៉ាត** | អគ្គនាយករង នៃអាជ្ញាធរអប្សរា | សមាជិក |
| ៦-ឯកឧត្តម | **អ៊ុង អឿន** | អភិបាលរងទី១ ខេត្តសៀមរាប | សមាជិក |
| ៧-ឯកឧត្តម | **ម៉ៅ នឹម** | អភិបាលរងទី១ ខេត្តឧត្តរមានជ័យ | សមាជិក |
| ៨-លោក | **ឡេង សុខា** | អគ្គលេខាធិការរងនៃអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| ៩-លោក | **ឃុយ ហៀង** | ប្រធាននាយកដ្ឋានគមនាគមន៍ និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០-លោក | **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១-លោក | **ធី សុគន្ធ** | ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២-លោក | **ឆា ជុំ** | ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ១៣-លោក | **លឹម ស៊ីដេនិន** | ប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ចធ្វើទំនាក់ទំនង សហការជាមួយសមភាគីថៃ និងដោះស្រាយរាល់ការងារ ដែលពាក់ព័ន្ធនឹងការអនុវត្តលើគំរោងសាងសង់ផ្លូវជាតិលេខ៦៧ ( ប្រកសាងាំ អន្លង់វែង សៀមរាប ) និងធ្វើរបាយការណ៍អំពីលទ្ធផលការងារតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រីជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តសៀមរាប អភិបាលខេត្តឧត្តរមានជ័យ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៣

**ហ៊ុន សែន**

កន្លែងទទួលៈ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៣
- ឯកសារ- កាលប្បវត្តិ